ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

នស/រកម/០៦៩៥/០៣.

# ព្រះរាជក្រម

យើង

ព្រះបាទសម្ដេចព្រះ នរោត្តម សីហនុ វរ្ម័ន

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

******

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- យោងតាមព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- តាមសេចក្ដីក្រាបបង្គំទូលស្នើសុំអំពី សម្ដេចនាយករដ្ឋមន្ត្រីទាំងពីរ និង អំពីរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

## ប្រកាសឱ្យប្រើ

ច្បាប់ដែលបានអនុម័តដោយរដ្ឋសភា នៅថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ ១៩៩៥ ស្ដីពីសភាពាណិជ្ជកម្ម ដែលមានសេចក្ដីទាំងស្រុងដូចតទៅ :

# ច្បាប់

## ស្តីពី

## សភាពាណិជ្ជកម្ម

# ជំពូកទី ១
## ការរៀបចំនិងការប្រព្រឹត្តទៅនៃសភាពាណិជ្ជកម្ម

មាត្រា ១.-

សភាពាណិជ្ជកម្ម គឺជាគ្រឹះស្ថានសាធារណៈនៅក្រោមអាណាព្យាបាលនៃក្រសួង ពាណិជ្ជកម្ម ដែលធ្វើសកម្មភាពដើម្បីជាផលប្រយោជន៍ខាងវិស័យពាណិជ្ជកម្ម ឧស្សាហកម្ម កសិកម្ម សិប្បកម្ម និងសេវាកម្មក្នុងមណ្ឌលរបស់ខ្លួន ។

នៅតាមខេត្ត ក្រុងនីមួយៗមានសភាពាណិជ្ជកម្មមួយ។ប៉ុន្តែមណ្ឌលនៃសភាពាណិជ្ជកម្មមួយអាចលាតសន្ធឹងទៅខេត្ត ក្រុងច្រើនបានកាលណាស្ថានការណ៍សេដ្ឋកិច្ចតម្រូវឲ្យធ្វើដូច្នេះ ។

មាត្រា ២.-

សភាពាណិជ្ជកម្មនៅតាមខេត្ត ក្រុងនីមួយៗ ត្រូវបង្កើតឡើងដោយអនុក្រឹត្យតាមសំណើ របស់ក្រសួងពាណិជ្ជកម្ម ។ ព្រំដែនមណ្ឌលនៃសភាពាណិជ្ជកម្មនីមួយៗត្រូវកំណត់ឡើងដោយ អនុក្រឹត្យដែលបង្កើតសភានោះ ។

មាត្រា ៣.-

សភាពាណិជ្ជកម្មនីមួយៗ ត្រូវគ្រប់គ្រងដោយការិយាល័យមួយ ដឹកនាំដោយប្រធានមួយរូបនិងអនុប្រធានមួយរូបឬច្រើនរូប ។

ចំនួនសមាជិកនៃការិយាល័យ ទម្រង់បែបបទនៃការជ្រើសតាំងប្រធានព្រមទាំងការប្រព្រឹត្តទៅនៃការិយាល័យនេះត្រូវកំណត់ដោយបទបញ្ជាផ្ទៃក្នុង របស់សភាពាណិជ្ជកម្មដែលមានទម្រង់ដូចគ្នាតែមួយសំរាប់សភាពាណិជ្ជកម្មទូទៅនិងមាន ការយល់ព្រមពីគណៈរដ្ឋមន្ត្រី តាមសំណើរបស់ក្រសួងពាណិជ្ជកម្ម ។

មាត្រា ៤.-

សភាពាណិជ្ជកម្មមានសមាជិកសញ្ជាតិជាខ្មែរ ត្រូវបានជ្រើសតាំងដោយការបោះឆ្នោត ។ អាណត្តិ ចំនួនសមាជិក របៀបរបប និងការរៀបចំការបោះឆ្នោតត្រូវកំណត់ដោយអនុក្រឹត្យ ។

មាត្រា ៥.-

នៅអមសមាជិកជ្រើសតាំងដោយការបោះឆ្នោតសភាពាណិជ្ជកម្មមានសមាជិកទីប្រឹក្សា មួយចំនួនទៀត ដែលចូលរួមក្នុងការពិភាក្សា តែមានភារកិច្ចត្រឹមតែជាអ្នកផ្តល់មតិប៉ុណ្ណោះ ។

ចំនួននៃទីប្រឹក្សា មិនអាចលើសពីចំនួនសមាជិកជ្រើសតាំងដោយការបោះឆ្នោតឡើយ។ទីប្រឹក្សាទាំងនេះត្រូវបានតែងតាំងនៅពេលផ្លាស់សភាជាថ្មីម្តងៗ ។ ទីប្រឹក្សាត្រូវជ្រើសរើសក្នុងចំណោម ៖

១- តំណាងអង្គការ ឬតំណាងសមាគម ម្ចាស់សហគ្រាសពាណិជ្ជកម្ម ឧស្សាហកម្ម កសិកម្ម សិប្បកម្ម និងសេវាកម្ម ។
២- តំណាងក្រុមប្រឹក្សាដឹកនាំនៃសហគ្រាសពាណិជ្ជកម្ម ឧស្សាហកម្ម កសិកម្ម សិប្បកម្ម និងសេវាកម្ម ។
៣- តំណាងបុគ្គលិកនៃសហគ្រាសពាណិជ្ជកម្ម ឧស្សាហកម្ម កសិកម្ម សិប្បកម្ម និង សេវាកម្ម ។

ក្រសួងពាណិជ្ជកម្មកំណត់តាមប្រកាស បន្ទាប់ពីបានទទួលសេចក្តីស្នើពីសភាពាណិជ្ជកម្ម នូវ ៖

- ចំនួនទីប្រឹក្សា
- ចំនួនសមាជិកប្រភេទនីមួយៗ ដូចមានចែងខាងលើនេះ
- បញ្ជីនៃអង្គការឬនៃសមាគមដែលមានសិទ្ធិចាត់តាំងតំណាងជាទីប្រឹក្សា ។

មាត្រា ៦.-

អភិបាលខេត្ត ក្រុង ឬតំណាង និងតំណាងក្រសួងពាណិជ្ជកម្មមានសិទ្ធិចូលរួមក្នុងសម័យប្រជុំសភាពាណិជ្ជកម្ម តែមានភារកិច្ចត្រឹមតែជាអ្នកផ្តល់មតិប៉ុណ្ណោះ ។

មាត្រា ៧.-

សមាជិកជ្រើសតាំងនិងទីប្រឹក្សានៃសភាពាណិជ្ជកម្ម បំពេញមុខងាររបស់ខ្លួន ដោយមិនយកប្រាក់ខែឬប្រាក់បំណាច់អ្វីឡើយ ។

មាត្រា ៨.-

សភាពាណិជ្ជកម្មទាំងឡាយអាចសហការគ្នាតាមរយៈប្រធានរបស់ខ្លួនក្នុងក្របខ័ណ្ឌនៃ ភារកិច្ចស្តីពីបញ្ហាទាំងឡាយដែលពាក់ព័ន្ធទៅនឹងមណ្ឌលរៀងៗខ្លួន ។

# ជំពូកទី ២
## ភារកិច្ចរបស់សភាពាណិជ្ជកម្ម

មាត្រា ៩.-

សភាពាណិជ្ជកម្មមានភារកិច្ចដូចតទៅ ៖

១- ធ្វើទំនាក់ទំនងជាមួយនឹងប្រភពសេដ្ឋកិច្ចក្នុងប្រទេស និងក្រៅប្រទេស ដើម្បីស្រង់យកព័ត៌មានដែលពាក់ព័ន្ធនឹងកិច្ចអភិវឌ្ឍន៍សហគ្រាសជាតិ ។

២- បង្កើនប្រសិទ្ធភាពសហគ្រាសទាំងឡាយ ដើម្បីជាផលប្រយោជន៍ខាងវិស័យពាណិជ្ជកម្ម ឧស្សាហកម្ម កសិកម្ម សិប្បកម្ម សេវាកម្ម និងសេដ្ឋកិច្ចទូទៅ ដូចជាការរៀបចំផ្សព្វផ្សាយ នូវស្ថិតិពាណិជ្ជកម្ម និងសេដ្ឋកិច្ច ការសិក្សាស្រាវជ្រាវពិចារណាលើបញ្ហាសេដ្ឋកិច្ចនិងពាណិជ្ជកម្ម ការលើកតំកើងផ្នែកទេសចរណ៍ ។

៣- ផ្តល់ជូនរាជរដ្ឋាភិបាលនិងអាជ្ញាធរខេត្ត ក្រុង នូវយោបល់និងព័ត៌មានទាំងឡាយស្តីពី បញ្ហាពាណិជ្ជកម្ម ឧស្សាហកម្ម កសិកម្ម សិប្បកម្ម និងសេវាកម្ម ។

៤- ដើរតួជាអ្នកតំណាងសហគមន៍ពាណិជ្ជកម្ម ឧស្សាហកម្ម កសិកម្ម សិប្បកម្ម និង សេវាកម្មសំរាប់សំរបសំរួលកិច្ចការជាមួយរដ្ឋអំណាច ។

៥- ធានារ៉ាប់រងនូវការគ្រប់គ្រងសេវា ធានា និង អនុវត្តការងារចាំបាច់ ដែលជាផលប្រយោជន៍ក្នុងសមត្ថកិច្ចរបស់ខ្លួន ។

៦- ដើរតួជាអាជ្ញាកណ្តាលក្នុងការដោះស្រាយវិវាទពាណិជ្ជកម្ម ។

មាត្រា ១០.-

សភាពាណិជ្ជកម្មត្រូវផ្តល់យោបល់ :

១- អំពីគំរោងបទបញ្ញាទាំងឡាយផ្នែកសេដ្ឋកិច្ច និងពាណិជ្ជកម្ម ។

២- អំពីតម្លៃ និង អាករលើសេវាទាំងឡាយដែលរដ្ឋធ្វើសម្បទានអោយសហគ្រាសណាមួយ ។

៣- អំពីផលប្រយោជន៍ នៃគំរោងសំណង់សាធារណការ ដែលត្រូវអនុវត្តក្នុងមណ្ឌលនីមួយៗព្រមទាំងពន្ធអាករដែលត្រូវប្រមូលយកពីអ្នកប្រើប្រាស់ ដើម្បីកសាងសំណង់នោះ ។

៤- អំពីគំរោងវិសោធនកម្មច្បាប់ វិស័យគយ ពាណិជ្ជកម្ម និងសេដ្ឋកិច្ច ។

៥- អំពីការកំណត់អត្រាពន្ធគយ ។

ម្យ៉ាងទៀត តាមគំនិតផ្តួចផ្តើមផ្ទាល់របស់ខ្លួន សភាពាណិជ្ជកម្មអាចធ្វើសំណូមពរទាំងឡាយដែលទាក់ទងនឹងសកម្មភាពពាណិជ្ជកម្ម ឧស្សាហកម្ម កសិកម្ម សិប្បកម្ម និងសេវាកម្ម ។

មាត្រា ១១.-

តាមសំណូមពរម្ចាស់អំណោយឯកជន ឬរដ្ឋ ព្រមទាំងមានការយល់ព្រមពីគណៈរដ្ឋមន្ត្រី តាមសំណើរបស់ក្រសួងពាណិជ្ជកម្ម សភាពាណិជ្ជកម្មអាចបង្កើត ឬគ្រប់គ្រងគ្រឹះស្ថានពាណិជ្ជកម្ម ឧស្សាហកម្ម កសិកម្ម សិប្បកម្ម និងសេវាកម្ម ទោះជារបស់រដ្ឋក្តី របស់ឯកជនក្តី ដូចជាឃ្លាំងផ្ទុកទំនិញ សាលលក់ឥវ៉ាន់ ភណ្ឌាគារពិព័រណ៍អចិន្ត្រៃយ៍ សារមន្ទីរពាណិជ្ជកម្ម សាលាបណ្តុះបណ្តាលវិជ្ជាជីវៈ ពាណិជ្ជកម្ម និងឧស្សាហកម្ម ទីផ្សារសាធារណៈ មហាសាលសំរាប់ទេសចរណ៍ ។

មាត្រា ១២.-

សភាពាណិជ្ជកម្មអាចទិញ ឬសង់អាគារសំរាប់ប្រើប្រាស់ជារបស់ខ្លួនផ្ទាល់ ឬសំរាប់ជួល ធ្វើអាជីវកម្ម បើគ្មានការជំទាស់ពីគណៈរដ្ឋមន្ត្រី តាមសំណើរបស់ក្រសួង

ពាណិជ្ជកម្ម ។

មាត្រា ១៣.-

ដោយមានសេចក្តីសំរេចរបស់គណៈរដ្ឋមន្ត្រី តាមសំណើរបស់ក្រសួងពាណិជ្ជកម្ម សភាពាណិជ្ជកម្មអាចចូលរួមក្នុងការដេញថ្លៃជាសាធារណៈ ដើម្បីទទួលភារៈជាសម្បទានិកនៃសំណង់ សាធារណការទាំងឡាយ ឬទទួលបន្ទុកធ្វើសេវាសាធារណៈ ។

មាត្រា ១៤.-

រៀងរាល់ឆ្នាំ សភាពាណិជ្ជកម្មត្រូវបញ្ជូនរបាយការណ៍ទូទៅមួយ ស្តីពីសកម្មភាពរបស់ខ្លួនទៅក្រសួងពាណិជ្ជកម្ម ដែលមានភាតព្វកិច្ចផ្សព្វផ្សាយជា សាធារណៈនូវរបាយការណ៍នោះ ។

## ជំពូកទី ៣
## ហិរញ្ញប្បទាន

មាត្រា ១៥.-

ចំណាយសំរាប់ការប្រព្រឹត្តទៅនៃសភាពាណិជ្ជកម្ម ត្រូវផ្គត់ផ្គង់ដោយភាគទានប្រចាំឆ្នាំ របស់សមាជិក បូករួមជាមួយនឹងចំណូល ព្រមទាំងវិភាគទានមកពីប្រភពផ្សេងៗទៀត ។

មាត្រា ១៦.-

បើគ្មានការជំទាស់ពីក្រសួងពាណិជ្ជកម្ម សភាពាណិជ្ជកម្មអាចខ្ចីប្រាក់ដើម្បីរ៉ាប់រងចំណាយនានាគ្រប់វិស័យដែលពាក់ព័ន្ធនឹងភារកិច្ចបន្ថែមរបស់ខ្លួន ដែលមានចែងក្នុងមាត្រា ១១ និង ១២ លើកលែងតែចំណាយសំរាប់ការប្រព្រឹត្តទៅ ដែលមានចែងក្នុងមាត្រា ១៥ នៃច្បាប់នេះ ។

មាត្រា ១៧.-

សំណាងចំណុលទាំងដើមទាំងការដែលសភាពាណិជ្ជកម្មបានខ្ចី ត្រូវធានារ៉ាប់រង ដោយប្រាក់ចំណូលនៃអាជីវកម្ម ។

មាត្រា ១៨.-

បើគ្មានការជំទាស់ពីក្រសួងពាណិជ្ជកម្ម សភាពាណិជ្ជកម្មមួយចំនួនអាចនឹងខ្ចីឥណទានរួម ដើម្បីយកមកបង្កើត ផ្គត់ផ្គង់គ្រឹះស្ថានសេវា ឬសំណង់ដែលជាប្រយោជន៍រួម របស់សភាពាណិជ្ជកម្មទាំងនោះ ។

សំណាងចំណុលនេះត្រូវរ៉ាប់រងដោយប្រាក់ចំណូលរួមនៃអាជីវកម្ម ។

មាត្រា ១៩.-

ការខ្ចីប្រាក់ដូចមានចែងក្នុងមាត្រា ១៦ ១៧ និង ១៨ ខាងលើនេះ អាចធ្វើតាមរយៈ ធនាគារណាដែលផ្តល់អត្ថប្រយោជន៍ប្រសើរជាងគេ ។

មាត្រា ២០.-

ក្រៅពីថវិកាសាមញ្ញ សភាពាណិជ្ជកម្មរៀបចំនូវថវិកាពិសេសសំរាប់គ្រឹះស្ថានពាណិជ្ជកម្ម ឧស្សាហកម្ម កសិកម្ម និងសិប្បកម្មដែលខ្លួនគ្រប់គ្រង ។

ក្នុងរយៈពេល ៦ ខែដំបូងនៃឆ្នាំនីមួយៗ សភាពាណិជ្ជកម្មត្រូវផ្ញើជូនក្រសួងពាណិជ្ជកម្ម ដើម្បីសុំការយល់ព្រមលើរបាយការណ៍ស្តីពីចំណូលនិងចំណាយនៃឆ្នាំមុនហើយនិងគំរោងថវិកាចំណូលចំណាយនៃឆ្នាំបន្ទាប់ដោយមានឯកសារគណនេយ្យភ្ជាប់ជាមួយផង ។

ម្យ៉ាងទៀតសភាពាណិជ្ជកម្មត្រូវផ្ញើតារាងរំលោះប្រាក់ខ្ចីជូនទៅក្រសួងពាណិជ្ជកម្មជារៀងរាល់ឆ្នាំ ។

សភាពាណិជ្ជកម្មអាចបំរុងទុកទឹកប្រាក់ទាំងអស់ ឬមួយភាគនៃចំណូលលើស ដែលបានពីការគ្រប់គ្រងសេវាធម្មតាសំរាប់បង្កើតមូលនិធិពិសេសមួយ ដើម្បីផ្គត់ផ្គត់ចំណាយជាបន្ទាន់ដែលមិនបានគ្រោងទុក ។ ទោះក្នុងករណីណាក្តី ចំនួនមូលនិធិបំរុងនេះមិនអាចខ្ពស់ជាង ២០ ភាគរយនៃធនធានប្រចាំឆ្នាំរបស់ថវិកានោះបានឡើយ ។

## ជំពូកទី ៤
## អវសានប្បញ្ញត្តិ

**មាត្រា ២១.-**

បទបញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ២២.-**

ច្បាប់នេះត្រូវប្រកាសទុកជាការប្រញាប់ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ១៩៩៥

ព្រះហស្តលេខា

**នរោត្តម សីហនុ**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រីទី១** **នាយករដ្ឋមន្ត្រីទី២**

ព្រះហស្តលេខា ហត្ថលេខា

**នរោត្តម រណឫទ្ធិ** **ហ៊ុន សែន**

បានបង្គំទូលថ្វាយនិងជំរាបជូន
សម្តេចនាយករដ្ឋមន្ត្រីទី១និងទី២
រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

ហត្ថលេខា

**ចម ប្រសិទ្ធ**

លេខៈ....៣៣....ច.ល.

ចម្លងត្រឹមត្រូវ
ភ្នំពេញ ថ្ងៃទី ... ខែ មិថុនា ឆ្នាំ ១៩៩៥
អគ្គលេខាធិការរាជរដ្ឋាភិបាល
អគ្គលេខាធិការរង
ស៊ុន សារ